ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៨៩/១៩ - ខ្សែមខ្សែប៉ (ខេមបូឌា) ឯ.ក

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **យូ សួនទី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ស៊ីន គីមស៊ាន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ខ្សែមខ្សែប៉ (ខេមបូឌា) ឯ.ក**

អាសយដ្ឋាន ៖ ភូមិក្បាលដំរី២ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៧១ ៦៨ ៨៦ ៨៨៦ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ៖

| | |
|---|---|
| ១- លោកមេធាវី ហំ ភា | មេធាវី |
| ២- លោក ត្រេង ម៉េង | ប្រធានផ្នែកទូទៅ |
| ៣- លោកស្រី លឹម ដារ៉ែ | ប្រធានរដ្ឋបាល |
| ៤- លោក YEH YANGKE | គណនេយ្យ |
| ៥- លោក KAO MINGGHIEH | គណនេយ្យ |

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខ្សែមខ្សែប៉ (ខេមបូឌា) ឯ.ក**

អាសយដ្ឋាន ៖ ភូមិក្បាលដំរី២ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៩៧ ៥៥ ៦៥ ៦៣៥ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖ អវត្តមាន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ស្នើសុំឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យកម្មករបានប្រើការឈប់សម្រាកប្រចាំឆ្នាំចំនួន ៣ថ្ងៃ ក្នុងថ្ងៃឈប់សម្រាកបុណ្យភ្ជុំបិណ្ឌ។

២- ស្នើសុំនៅពេលក្រុមហ៊ុនបញ្ឈប់កម្មករដែលមិនទាន់ដល់កិច្ចសន្យា សុំក្រុមហ៊ុនសងកិច្ចសន្យាដែលនៅសល់។

៣- ស្នើសុំក្រុមហ៊ុន កុំព្រមានកម្មករនៅពេលកម្មករភ្លេចកាត ភ្លេចកន្សែងម្តងម្កាល។

៤- ស្នើសុំក្រុមហ៊ុន កុំព្រមានកម្មករដែលទៅបន្ទប់ទឹកលើសពី ៣ដង។

៥- ស្នើសុំក្រុមហ៊ុនផ្តល់ថ្នាំពេទ្យឱ្យបានគ្រប់គ្រាន់ជូនកម្មករ។

៦- ស្នើសុំក្រុមហ៊ុន នៅពេលអត់ការងារធ្វើ សុំកុំកាត់កងបំណាច់ឆ្នាំ។

៧- ស្នើសុំក្រុមហ៊ុនសាងសងទារកដ្ឋាន ឬបន្ទប់បំបៅកូន បើគ្មានលទ្ធភាពទេ ស្នើសុំលុយទឹកដោះគោក្នុង១ខែ ចំនួន ៣០ ដុល្លារ។

៨- ស្នើសុំឱ្យក្រុមហ៊ុនថែមម៉ោងស្ថិតលើគោលការណ៍ស្ម័គ្រចិត្ត។

៩- ស្នើសុំក្រុមហ៊ុននៅពេលដែលកម្មករឈឺមានសំបុត្រពេទ្យត្រឹមត្រូវ សុំកុំកាត់លុយកម្មករ។

១០- ស្នើសុំឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករ-កម្មការិនីនៅក្នុងអំឡុងពេលធ្វើកូដកម្ម។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨១/១៩ ក.ប/ប្រ.ក.រ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០១៩ (អាណត្តិទី១៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ឡែមឡៃច៍ (ខេមបូឌា) ឯ.ក លេខ ១០០៣ ក.ប/អក/វក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សា-អាជ្ញាកណ្តាល នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវ[illegible] (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃចន្ទ ១០រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី៖**

នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៩ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្ដឹងរបស់កម្មករនិយោជិត នៃក្រុមហ៊ុន ឡែមឡែប៉ (ខេមបូឌា) ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៩ លើការទាមទារលក្ខខណ្ឌការងារ និងអត្ថប្រយោជន៍ ចំនួន ១០ ចំណុច។ បន្ទាប់ពីបានទទួលពាក្យបណ្ដឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះ និងបានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកធ្វើការផ្សះផ្សានៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៩ ប៉ុន្តែមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ចំណុចមិនសះជាដែលនៅសល់ចំនួន ១០ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ តាមរយៈរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ឡែមឡែប៉ (ខេមបូឌា) លេខ ១០០៣ ក.ប/អក/វក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩។

បន្ទាប់ពីបានទទួលសំណុំរឿងនេះមក ក្រុមអាជ្ញាកណ្ដាលត្រូវបានបង្កើតឡើងនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩។ នៅមុនពេលក្រុមអាជ្ញាកណ្ដាលត្រូវបានបង្កើតឡើង លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានទទួលលិខិតមួយច្បាប់ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ក្រុមហ៊ុន ឡែមឡែប៉ (ខេមបូឌា) ដែលមានកម្មវត្ថុ សំណើសុំចេញសេចក្ដីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន ឡែមឡែប៉ (ខេមបូឌា)។ ហេតុនេះ នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចេញសេចក្ដីបញ្ជា លេខ ០១១/១៩ កបអ. ឱ្យផ្អាកជាបន្ទាន់ នូវការធ្វើកូដកម្មរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ឡែមឡែប៉ (ខេមបូឌា) រហូតដល់នីតិវិធីនៃអាជ្ញាកណ្ដាលត្រូវបានបញ្ចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីព្រឹកថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៩ តទៅ តាមវេនរបស់ខ្លួន។ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានទូរស័ព្ទទៅភាគីទាំងពីរដើម្បីសាកសួរព័ត៌មានពីការធ្វើកូដកម្ម ភាគីទាំងពីរបានបញ្ជាក់ថា កូដករទាំងអស់បានចូលធ្វើការវិញអស់ហើយ។

លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានអញ្ជើញភាគីកម្មករនិយោជិត និងភាគីនិយោជក មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជា ចំនួន ១០ ចំណុចនេះ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល តាមរយៈលិខិតអញ្ជើញលេខ ៥០៨ កប/អក/វក/លកអ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ទៅភាគីនិយោជក និងលិខិតអញ្ជើញលេខ ៥០៩ កប/អក/វក/លកអ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ទៅភាគីកម្មករនិយោជិត។

នៅថ្ងៃសវនាការ មុនម៉ោងកំណត់សវនាការ មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានទំនាក់ទំនងតាមទូរស័ព្ទទៅកាន់ភាគីកម្មករនិយោជិត មានលោកស្រី ឌុល លីណា ជាតំណាងភាគីកម្មករនិយោជិត សួរនាំអំពីការធ្វើដំណើរមកចូលរួមសវនាការ ថាតើពួកគាត់អញ្ជើញមកដល់ណាហើយ ដើម្បីចូលរួមសវនាការអាជ្ញាកណ្ដាល។ លោកស្រី ឌុល លីណា បានប្រាប់មកមន្ត្រីលេខាធិការដ្ឋានថា មិនបានមកចូលរួមសវនការទេ ដោយសារគាត់កំពុងនៅស្រុកកំណើត ហើយកម្មករនិយោជិតដែលពាក់ព័ន្ធផ្សេងទៀតបានលាឈប់ពីការងារអស់ហើយ ហេតុនេះនៅថ្ងៃនេះមិនមានកម្មករនិយោជិតចូលរួមសវនាការទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណា ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិរបស់លោក LIAO HIS CHE ជានាយកក្រុមហ៊ុន ឡែមឡែប៍ (ខេមបូឌា) ឯ.ក គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំផ្ទេរសិទ្ធិជូនលោក គ្រេង ម៉េង ជាប្រធានផ្នែកទូទៅ មានសិទ្ធិ និងអំណាចពេញលេញក្នុងការដោះស្រាយរាល់បញ្ហាវិវាទការងារ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩។

២- លិខិតផ្ទេរសិទ្ធិរបស់ក្រុមហ៊ុន ឡែមឡែប៍ (ខេមបូឌា) ឯ.ក ផ្ទេរសិទ្ធិជូនលោកមេធាវី ហំ ភា ជាអ្នកតំណាងដោយអាណត្តិរបស់ក្រុមហ៊ុន ឡែមឡែប៍ (ខេមបូឌា) ឯ.ក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០១៩។

៣- លិខិតចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ របស់ក្រុមហ៊ុន ឡែមឡែប៍ (ខេមបូឌា) ឯ.ក គោរពជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំចេញសេចក្តីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន ឡែមឡែប៍ (ខេមបូឌា) ឯ.ក។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖** គ្មាន

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ឡែមឡែប៍ (ខេមបូឌា) ឯ.ក លេខ ១០០៣ ក.ប/អក/វក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ឡែមឡែប៍ (ខេមបូឌា) ឯ.ក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ឡែមឡែប៍ (ខេមបូឌា) ឯ.ក លេខ ០១៧/១៩ កប/អក/វក/កវក២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ ២០១៩ របស់នាយកដ្ឋានវិវាទការងារ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតលេខ ៤៩៥ កប/អក/វក/លកអ. ចុះព្រហស្បតិ៍ ១៤កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ជម្រាបមក អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ឡែមឡែប៍ (ខេមបូឌា) ឯ.ក ស្តីពីការជ្រើសរើសអាជ្ញាកណ្តាល។

២- កំណត់ហេតុស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាល ពីបញ្ជីឈ្មោះអាជ្ញាកណ្តាលស្នើដោយសហជីព កម្មករនិយោជិត ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩។

៣- សេចក្តីបញ្ជាក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០១១/១៩ កបអ. ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ ២០១៩។

៤- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៥០៨ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ៤រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩។

THE ARBITRATION COUNCIL

៥- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៥០៩ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ៤រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩។

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទដែលចែងនៅក្នុងរបាយការណ៍មិនសះជារបស់នាយកដ្ឋានវិវាទការងារ ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារភាគីកម្មករនិយោជិត ដែលជាដើមបណ្តឹងមិនបានចូលរួមនីតិវិធីក្នុងសវនាការ។

**ហេតុផលនៃសេចក្តីសម្រេច ៖**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ ក្នុងករណីអវត្តមានរបស់ភាគីកម្មករនិយោជិត ដែលជាដើមបណ្តឹង?

ប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ប្រការ ២១ ចែងថា ៖ *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់"* ។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា ៖ *"ប្រសិនបើភាគីណាមួយមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាលមុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន"*។

នៅក្នុងសំណុំរឿងលេខ ១៦/០៧-ឡូទូសគី, លេខ ២៧/០៧-អ៊ឹម និង វ៉ េ ៣, លេខ ១៣៨/០៨-ម៉ាលីន, លេខ ១១/១១-ជូន តិចថាយល៍, លេខ ១៣១/១២-ម៉ាស្ទ័រ & ហ្វ្រែង, លេខ ១០៨/១៣-អាត់តូ និងលេខ ៣៣២/១៤-ធី & ខេ ហ្គាមេន ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយប្រការ ២១ ខាងលើនេះថា មានលក្ខខណ្ឌបីដែលត្រូវបំពេញ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចមិនបន្តដំណើរការអាជ្ញាកណ្តាល គឺ "លក្ខខណ្ឌទី១ ៖ ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ, លក្ខខណ្ឌទី២ ៖ ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល និងលក្ខខណ្ឌទី៣ ៖ ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន" ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗ ខាងលើដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះ ត្រូវបានបំពេញដែរ ឬទេ?

**លក្ខខណ្ឌទី ១ ៖ ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ**

លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីកម្មករនិយោជិត ដើម្បីឱ្យមកចូលរួមក្នុងសវនាការអាជ្ញាកណ្តាលយ៉ាងត្រឹមត្រូវ តាមរយៈលិខិតអញ្ជើញលេខ ៥០៩ កប/អក/វក/លកអ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩។ នៅក្នុងលិខិតនោះ បានបញ្ជាក់យ៉ាងច្បាស់លាស់អំពីកាលបរិច្ឆេទនៃសវនាការ គឺនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩។ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ដដែល មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញា

THE ARBITRATION COUNCIL

កណ្តាលបានទាក់ទងទៅកាន់តំណាងកម្មករនិយោជិតចំនួន ៣រូប គឺលោកស្រី ឌុល លីណា, ឆាង ស្រីមុំ និង ញឹប សៀប ដើម្បីប្រាប់ពីថ្ងៃសវនាការ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីដើមបណ្តឹងពិតជាទទួលបានការអញ្ជើញត្រឹមត្រូវ ពីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ឱ្យចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិតប្រាកដមែន។ ហេតុនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី ២ ៖ ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា យោងប្រការ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលតម្រូវឱ្យភាគីត្រូវបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល នោះគឺភាគីត្រូវតែមាន (១) វត្តមាននៅក្នុងសវនាការ និង (២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាល រហូតចប់សព្វគ្រប់។

ក្នុងករណីនេះ ភាគីកម្មករនិយោជិត មិនមានវត្តមាននៅក្នុងសវនាការទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញា-កណ្តាលយល់ឃើញថា ភាគីដើមបណ្តឹងមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល តាមខ្លឹមសារប្រការ ២១ នៃប្រកាសលេខ ០៩៩ លើនេះទេ។ ដូចនេះ លក្ខខណ្ឌទី២ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី ៣ ៖ ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតមិនមានវត្តមាននៅក្នុងសវនាការទេ ដោយបានបញ្ជាក់តាមទូរស័ព្ទជាមួយមន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលថា គាត់កំពុងនៅស្រុកកំណើត និងមិនមានកម្មករនិយោជិតណាម្នាក់មកចូលរួមសវនាការទេ។ ពាក់ព័ន្ធនឹងការលើកឡើងរបស់កម្មករនិយោជិត ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ដើមបណ្តឹងមិនមានហេតុផលត្រឹមត្រូវសម្រាប់ការមិនមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ ដូច្នេះ លក្ខខណ្ឌទី៣ ត្រូវបានបំពេញ។

សរុបសេចក្តីមក លក្ខខណ្ឌទាំងបី ដែលមានចែងក្នុងប្រការ២១ នៃប្រកាសលេខ ០៩៩ ខាងលើ ត្រូវបានបំពេញ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា តាមនីតិវិធីនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ភាគីដើមបណ្តឹង និងភាគីចុងចម្លើយនៃសំណុំរឿងវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល មានកាតព្វកិច្ចបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបកស្រាយ បង្ហាញ និងផ្តល់អំណះអំណាង សម្រាប់ការទាមទាររបស់ខ្លួន ក៏ដូចជាផ្តល់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗ ដែលពាក់ព័ន្ធនឹងចំណុចវិវាទ សម្រាប់ឱ្យក្រុមប្រឹក្សាអាជ្ញា-កណ្តាលធ្វើការពិចារណា និងសម្រេចសេចក្តី។

ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដែលពាក់ព័ន្ធនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីការពារបណ្តឹងទាមទាររបស់ខ្លួន។ ចំណែកឯភាគីចុងចម្លើយមានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដែលពាក់ព័ន្ធនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីដោះបន្ទុករបស់ខ្លួន ពីការទាមទារពីសំណាក់ដើមបណ្តឹង។

ក្នុងសំណុំរឿងនេះ ភាគីដើមបណ្តឹងមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដើម្បីបំពេញនូវកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាង ដើម្បីការពារបណ្តឹងរបស់ខ្លួនទេ។ លើសពីនេះ ភាគីដើមបណ្តឹងក៏មិនមានមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួននេះដែរ។ ហេតុនេះ ក្រុមប្រឹក្សា

THE ARBITRATION COUNCIL

អាជ្ញាកណ្តាលចាត់ទុកថា ភាគីដើមបណ្តឹងបានបោះបង់ចោលការទាមទាររបស់ខ្លួន។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនចាំបាច់បន្តដំណើរការអាជ្ញាកណ្តាលនោះទេ។

ហេតុនេះ ផ្អែកតាមវិធាន និងប្រកាស ព្រមទាំងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា ដើមបណ្តឹងបានបោះបង់ចោលពាក្យបណ្តឹងរបស់ខ្លួន។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់។

ហេតុដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ០៨៩/១៩- ឡែមឡែប៉ (ខេមបូឌា) នេះ។

## សម្រេច និង បង្គាប់

- បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៃសំណុំរឿងលេខ ០៨៩/១៩-ឡែមឡែប៉ (ខេមបូឌា) ឯ.ក។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក

ឈ្មោះ ៖ **យូ សួនទី**

ហត្ថលេខា: ------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ស៊ីន គីមស៊ាន**

ហត្ថលេខា: ------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា: ------------------------------------